# សេចក្តីជូនដំណឹងអំពីការពិគ្រោះថ្លៃ

## សហគមន៍កសិកម្មសែនហានចម្រើនផល
## មានបំណងអនុវត្តការងារសាងសង់ផ្ទះសំណាញ់ទំហំ ១០ម x ៣០ម ចំនួន១០ខ្នង

(១) សហគមន៍កសិកម្មសែនហានចម្រើនផល របស់យើងខ្ញុំបានទទួលមូលនិធិ ពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដែលផ្តល់ហិរញ្ញប្បទានដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) ហើយមានគោលបំណងប្រើប្រាស់មូលនិធិនេះ ដើម្បីធ្វើការទូទាត់នៅក្រោមកិច្ចសន្យាសម្រាប់ការងារសាងសង់ផ្ទះសំណាញ់ផលិតបន្លែសុវត្ថិភាព លេខកិច្ចសន្យា ១.១។ ទំហំការងារ និងការបរិយាយការងារសាងសង់ផ្ទះសំណាញ់ផលិតបន្លែសុវត្ថិភាព ត្រូវអនុវត្តទៅតាមប្រតិទិនការងារដូចមានរាយក្នុងទម្រង់ទី១៖ បញ្ជីប៉ាន់តម្លៃ និងប្រតិទិនការងារ។

(២) ការសាងសង់ផ្ទះសំណាញ់ផលិតបន្លែសុវត្ថិភាពមាន **រយៈពេល ៦០ថ្ងៃ** ចាប់ពីថ្ងៃបានចុះហត្ថលេខាលើកិច្ចសន្យា។

(៣) អ្នកទទួលកិច្ចការទាំងឡាយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានចំណាប់អារម្មណ៍ សូមអញ្ជើញមកទទួលឯកសារពិគ្រោះថ្លៃ (ដោយឥតគិតថ្លៃ) នៅ**សហគមន៍កសិកម្មសែនហានចម្រើនផល** ការិយាល័យសហគមន៍កសិកម្មសែនហានចម្រើនផល អាស័យដ្ឋាន **ភូមិដំណាក់ក្រយឹង ឃុំសំរោងលើ ស្រុកបន្ទាយមាស ខេត្តកំពត** លេខទូរសព្ទ ០១២ ៥៥៥ ២១៣។ អ្នកទទួលកិច្ចការអាចទាក់ទងទៅឈ្មោះ **អ៊ិន សុឃន** ជាជំនួយការលទ្ធកម្មតាមរយៈ លេខទូរសព្ទ ០៩៧ ៧៦៥៦១៨៨ ។

(៤) ដើម្បីទទួលបានឯកសារពិគ្រោះថ្លៃ អ្នកទទួលការត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- ជាក្រុមហ៊ុនសំណង់ឯកជន ក្រុមជាងម៉ៅការសាងសង់នៅក្នុងសហគមន៍ ដែលមានអត្តសញ្ញាណសម្គាល់ច្បាស់លាស់ដូចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (នៅមានសុពលភាព) មានបណ្ណប៉ាតង់ដែលមានសុពលភាព និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការសាងសង់ និងជូសជុលទៅតាមបញ្ជីប៉ាន់តម្លៃ និងលក្ខណៈបច្ចេកទេសដែលបានកំណត់ក្នុងឯកសារពិគ្រោះថ្លៃ។

- អ្នកទទួលកិច្ចការដែលត្រូវបានកំណត់ថាពាក់ព័ន្ធនឹងការក្លែងបន្លំ អំពើពុករលួយ និងអំពើឃុបឃិត ហើយស្ថិតក្នុងបញ្ជីហាមឃាត់ ក្នុងអំឡុងពេលធ្វើការដេញថ្លៃ នឹងមិនមានសិទ្ធិចូលរួមដេញថ្លៃឡើយ។

(៥) សំណើពិគ្រោះថ្លៃ និងតម្លៃក្នុងសំណើពិគ្រោះថ្លៃ ត្រូវមានសុពលភាព និងជាតម្លៃថេរសម្រាប់រយៈពេល **៦០ ថ្ងៃ** បន្ទាប់ពីថ្ងៃផុតកំណត់នៃការទទួលសំណើពិគ្រោះថ្លៃ។

(៦) តម្លៃសំណើពិគ្រោះថ្លៃត្រូវរួមបញ្ចូលនូវ ពន្ធអាករនានា ការដឹកជញ្ជូន ការធានារ៉ាប់រង និងចំណាយផ្សេងទៀត។

(៧) សំណើពិគ្រោះថ្លៃមិនអនុញ្ញាតិឱ្យមានការផ្លាស់ប្តូរឡើយ។

(៨) ការធានាលើគុណភាពសំណង់ត្រូវមានសុពលភាពយ៉ាងហោច ២៤ខែ។

(៩) សំណើពិគ្រោះថ្លៃច្បាប់ដើមត្រូវតែចុះហត្ថលេខា ដោយអ្នកដែលទទួលបានសិទ្ធិពេញលេញដើម្បីចុះហត្ថលេខាជំនួសមុខឱ្យអ្នកពិគ្រោះថ្លៃ។ អ្នកពិគ្រោះថ្លៃត្រូវដាក់សំណើពិគ្រោះថ្លៃក្នុងស្រោមសំបុត្រមួយបិទជិត ហើយបញ្ជូនឱ្យបានមុន ឬត្រឹមម៉ោង៖ **៣ : ០០ នាទី រសៀល ថ្ងៃ** ..**៤**.. **ខែ**..**៤**..... **ឆ្នាំ២០២៥** ទៅ**សហគមន៍កសិកម្មសែនហានចម្រើនផល** អាស័យដ្ឋាន **ភូមិដំណាក់ក្រយឹង ឃុំសំរោងលើ ខេត្តកំពត** លេខទូរសព្ទ០១២ ៥៥៥

សំណើពិគ្រោះដែលដាក់មកយឺតនឹងត្រូវបដិសេធ។ សំណើពិគ្រោះថ្លៃនឹងបើកជាសាធារណៈភ្លាមៗបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ឈប់ទទួលសំណើពិគ្រោះថ្លៃ នៅទីតាំងដែលបានបញ្ជាក់ខាងក្រោម នៅចំពោះមុខតំណាងអ្នកពិគ្រោះថ្លៃ ដែលអាចចូលរួមដោយផ្ទាល់។

១០.គ្រប់សំណើពិគ្រោះថ្លៃត្រូវភ្ជាប់មកជាមួយនូវ លិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃ ដូចមានចែងក្នុងឯកសារពិគ្រោះថ្លៃ។ សំណើពិគ្រោះថ្លៃដែលមិនភ្ជាប់មកជាមួយនូវ លិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃត្រូវបដិសេធ។

១១. សំណើពិគ្រោះថ្លៃដែលត្រូវបានវាយតម្លៃដោយធ្វើការកែតម្រូវការភ័ន្តច្រឡំនៃការគណនានានា ត្រូវបានធ្វើឡើយលើមូលដ្ឋានដូចខាងក្រោម៖

(ក) នៅពេលដែលមានការខុសគ្នារវាងចំនួនទឹកប្រាក់ជាតួលេខ និងចំនួនទឹកប្រាក់ជាអក្សរ នោះចំនួនទឹកប្រាក់ជាអក្សរនឹងយកជាបានការ។

(ខ) នៅពេលដែលមានការខុសគ្នារវាងថ្លៃឯកតា និងតម្លៃសរុបនៃមុខទំនិញនីមួយៗ ដែលបានមកពីផលគុណថ្លៃឯកតានឹងបរិមាណ នោះថ្លៃឯកតានឹងយកជាគោល។

ប្រសិនបើអ្នកពិគ្រោះថ្លៃបដិសេធមិនទទួលយកការកែតម្រូវ សំណើពិគ្រោះថ្លៃរបស់គេត្រូវបានបដិសេធ ហើយលិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃត្រូវបានអនុវត្ត។

១២.សហគមន៍កសិកម្ម ត្រូវសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកពិគ្រោះថ្លៃណាដែលសំណើពិគ្រោះថ្លៃរបស់គេត្រូវបានកំណត់ថាមានការឆ្លើយតបច្រើន ស្របទៅតាមបទដ្ឋាន និងលក្ខណៈបច្ចេកទេស និងបានដាក់តម្លៃពិគ្រោះថ្លៃដែលត្រូវបានវាយតម្លៃថាទាបសមស្របជាងគេ។

១៣. ករណីពិបាកណាមួយ ក្នុងការទទួលយកឯកសារពិគ្រោះថ្លៃ អ្នកមានចំណាប់អារម្មណ៍ចង់ចូលរួមពិគ្រោះថ្លៃទាំងអស់ អាចជូនដំណឹងជាលាយលក្ខអក្សរអំពីករណីពិបាកនោះជូន **លោកស្រី អេង វ៉ាណែត ជាប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម ទូរសព្ទលេខ** 071 29 39 560 អាស័យដ្ឋាន **ភូមិត្រមូង ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ** និងថតចម្លងផ្ញើជូនទៅ៖

ក្រុមរដ្ឋបាលគ្រប់គ្រងទុនវិនិយោគបន្ថែម នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដែលមានអាសយដ្ឋាននៅជាន់ផ្ទាល់ដីនៃនាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាយសដ្ឋាន៖# ២០០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

១៤.បន្ទាប់ពីការសម្រេចប្រគល់កិច្ចសន្យាត្រូវបានប្រកាស អ្នកពិគ្រោះថ្លៃដែលបរាជ័យមានសិទ្ធិស្នើសុំឱ្យមានការពន្យល់ ដើម្បីដឹងច្បាស់ពីមូលហេតុនៃការបរាជ័យនៃសំណើពិគ្រោះថ្លៃរបស់ខ្លួន ហើយគណៈកម្មការលទ្ធកម្មរបស់សហគមន៍កសិកម្ម មានកាតព្វកិច្ចផ្តល់ការពន្យល់នេះ។ ការសង្ងាត់ផ្ទាល់ខ្លួនរបស់អ្នកពិគ្រោះថ្លៃត្រូវបានរក្សាជាការសង្ងាត់មិនឱ្យភាគីផ្សេងទៀតបានដឹងឡើយ។

១៥.បណ្តឹងតវ៉ាត្រូវបញ្ជូនទៅប្រធានក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្ម ។ ប្រធានក្រុមប្រឹក្សាភិបាលនឹងធ្វើការអង្កេតលើមូលដ្ឋាននៃកាតវ៉ា និងធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល៧ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានបណ្តឹងតវ៉ានេះ លើកលែងតែក្នុងករណីការតវ៉ា ដែលបានទទួលក្នុងអំឡុងពេលវាយតម្លៃ ។ ការតវ៉ាដែលទទួលបានក្នុងអំឡុងពេលវាយតម្លៃសំណើពិគ្រោះ ត្រូវបានពិនិត្យមើលដោយគណកម្មការលទ្ធកម្មនៃសហគមន៍កសិកម្ម ហើយការឆ្លើយតប នឹងធ្វើឡើងបន្ទាប់ពីការវាយតម្លៃត្រូវបានបញ្ចប់ប៉ុណ្ណោះ។

ក្នុងករណីការឆ្លើយតបរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្ម មិនបំពេញតាមបំណងរបស់អ្នកពិគ្រោះថ្លៃចាញ់ ឬពុំមានការឆ្លើយតបណាមួយត្រូវបានធ្វើឡើងនោះទេ នោះអ្នកតវ៉ាត្រូវដាក់បណ្តឹងតវ៉ា ទៅកាន់